អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

# ការពិត និងតួលេខ#៤៧ ខែសីហា ឆ្នាំ២០២២



# ស្រ្តីនៅក្នុងសហគមន៍ក្រីក្រ
# បណ្ដាញសង្គម និងការគំរាមកំហែង



# អង្គការសហគមន៍ធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

អង្គការសមាគមធាងត្នោត (STT) ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តោតលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកលូតលាស់ខ្លួន ដោយផលិតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រ និងងាយរងគ្រោះឱ្យទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៥៥៥ ១៩៦៤

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ៖ www.teangtnaut.org

ហ្វេសប៊ុក៖ https://www.facebook.com/sttcambodia

ធ្វីទ័រ៖ https://twitter.com/STTCambodia

# មាតិកា

**មាតិកា** ............ i
**១. សេចក្តីផ្តើម** ............ ១
**២. គោលបំណង និងវិធីសាស្ត្រ** ............ ២
**៣. ច្បាប់ជាតិ និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិ** ............ ៣
ច្បាប់ជាតិ ............ ៣
កតិកាសញ្ញាអន្តរជាតិ ............ ៣
**៤. ការរកឃើញសំខាន់ៗ** ............ ៤
១. បានទទួលជំនួយពីអង្គការដៃគូ និងសប្បុរសជននានាក្នុងអំឡុងពេលបិទខ្ទប់ និងការសន្យាផ្តល់ដំណោះស្រាយដីធ្លីពីអាជ្ញាធរមូលដ្ឋាន ............ ៤
២. សិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិត្រូវបានរឹតត្បិត ក្រោមការបំភិតបំភ័យ និងគំរាមកំហែង ............ ៤
៣. ភ័យខ្លាចមិនហ៊ានបន្តសកម្មភាពរបស់ខ្លួនទៀត ............ ៦
៤. ការញុះញ៉ង់ លាបពណ៌នយោបាយ ពីសំណាក់អាជ្ញាធរមូលដ្ឋាន ............ ៧
**៥. សេចក្តីសន្និដ្ឋាន** ............ ៨
**៦. អនុសាសន៍** ............ ៩

## ១. សេចក្តីផ្តើម

ការសិក្សានេះ ធ្វើឡើងក្នុងគោលបំណងឈ្វេងយល់អំពីបទពិសោធន៍ក្នុងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដូចជា ហ្វេសប៊ុក (Facebook), វ៉ាត់អ៊ែប (WhatsApp) និង តេឡេក្រាម (Telegram ) ជាដើម របស់ស្ត្រីដែលរស់នៅក្នុងសហគមន៍ក្រីក្រ ដើម្បីបម្រើដល់ការងារ និងផលប្រយោជន៍ផ្សេងៗនៅក្នុងសហគមន៍ដែលពួកគេបាននឹងកំពុងរស់នៅ ជាពិសេសនៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩នេះ។

របាយការណ៍ការពិត និងតួលេខនេះ ផ្តោតលើការសិក្សាឈ្វេងយល់ពីស្ត្រីដែលជាសកម្មជន ឬជាអ្នកតំណាងសហគមន៍ក្រីក្ររបស់ខ្លួន និងបទពិសោធន៍ក្នុងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមដើម្បី ធ្វើការតស៊ូមតិ តាមដាន និងចែកចាយព័ត៌មាន គ្រប់គ្រងប្រភពទិន្នន័យ សុំជំនួយផ្សេងៗក្នុងអំឡុងពេលបិទខ្ទប់ និងរីករាលដាលនៃជម្ងឺកូវីដ-១៩ និងចែករំលែកព័ត៌មានអំពីបញ្ហាប្រឈមផ្សេងៗដូចជា បញ្ហាដីធ្លី ការទាមទារប្លង់កម្មសិទ្ធិ ហេដ្ឋារចនាសម្ព័ន្ធ គ្រឿងញៀន និងការរំលោភបំពាននានា ដែលកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគាត់ដល់សាធារណជនទូទៅ។ លទ្ធផលនៃរបាយការណ៍នេះបង្ហាញពីការរកឃើញមួយចំនួនដូចជា៖

- ការទទួលបានជំនួយពីអង្គការដៃគូ សប្បុរសជននានាក្នុងអំឡុងពេលបិទខ្ទប់ និងដំណោះស្រាយបញ្ហាក្នុងសហគមន៍។
- សិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិត្រូវបានរឹតត្បិត ដោយការការបំភិតបំភ័យ និងគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាន។
- មានការភ័យខ្លាចមិនហ៊ាន ឬថយចុះនូវឆន្ទៈ ក្នុងការធ្វើការតស៊ូមតិ និងបង្ហោះពីបញ្ហាប្រឈមរបស់សហគមន៍។ ដោយក្តីបារម្ភថានឹងមានការយាយី និងរំខានពីសំណាក់អាជ្ញាធរក្នុងមូលដ្ឋានរបស់ពួកគាត់។
- មានការញុះញង់ លាបពណ៌នយោបាយ និងការរើសអើងក្នុងការផ្តល់សេវាសាធារណៈពីសំណាក់អាជ្ញាធរមូលដ្ឋាន។

# ២. គោលបំណង និងវិធីសាស្ត្រ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈការសម្ភាសជាមួយ ស្ត្រី៦នាក់ ដែលជាស្ត្រីមេផ្ទះ ជាអ្នកស្ម័គ្រចិត្ត អ្នកតំណាងសហគមន៍ ប្រធានសហគមន៍ និងជាអនុប្រធានសហគមន៍ ដែលខ្លួនបាននិងកំពុងរស់នៅ។ ការសម្ភាសត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធទូរស័ព្ទ។ ការសិក្សាស្រាវជ្រាវ ដែលបង្ហាញនៅក្នុងរបាយការណ៍នេះធ្វើឡើងនៅក្នុងសហគមន៍ក្រីក្រចំនួន៦ ដែលស្ថិតនៅក្នុងខណ្ឌចំនួន៤ នៅរាជធានីភ្នំពេញ ដែលក្នុងនោះមានខណ្ឌមានជ័យ ខណ្ឌឬស្សីកែវ ខណ្ឌសែនសុខ និងខណ្ឌច្បារអំពៅ និងធ្វើឡើងនៅខែ ឧសភា ឆ្នាំ២០២២។ ការស្រាវជ្រាវមានលក្ខណៈគុណភាព ហើយសំណួរដែលប្រើក្នុងដំណើរការសម្ភាសគឺសំណួរបើក។ ការសម្ភាសនីមួយៗមាន រយៈពេល ចន្លោះពី២០-៣០នាទី ដែលក្រុមអ្នកស្រាវជ្រាវបានថតការសន្ទនាជាសំឡេង រួចធ្វើការកត់ត្រាកិច្ចសម្ភាសទាំងអស់ជាលាយល័ក្ខអក្សរ។ ក្រុមអ្នកស្រាវជ្រាវធ្វើការពន្យល់ប្រធានបទ នៃការសិក្សាស្រាវជ្រាវ និងទទួលបានការយល់ព្រមដោយផ្ទាល់មាត់ ពីអ្នកចូលរួមក្នុងបទសម្ភាស មុននឹងធ្វើការសម្ភាស និងថតសម្លេងនីមួយៗ។ ក្រុមអ្នកសម្ភាសក៏បានជូនព័ត៌មានជាមុនដល់អ្នកដែលត្រូវបានសម្ភាស អំពីការបោះពុម្ពផ្សាយខ្លឹមសារនៃកិច្ចសម្ភាស។ អត្តសញ្ញាណ និងឈ្មោះសហគមន៍របស់ស្ត្រីដែលបានផ្តល់កិច្ចសម្ភាសសម្រាប់របាយការណ៍នេះនឹងមិនត្រូវបានបញ្ចេញជាសាធារណៈទេ។ លទ្ធផលនៃការសិក្សានេះមិន តំណាងឱ្យស្ថិតិនៃបទពិសោធន៍ ផលវិបាក និងបញ្ហាប្រឈមដែលស្ត្រីរស់នៅក្នុងសហគមន៍ក្រីក្រទាំងអស់បាននិងកំពុងជួបប្រទះនោះទេ ប៉ុន្តែដើម្បីលើកយកនូវបញ្ហា ដែលស្ត្រីរស់នៅក្នុងសហគមន៍ក្រីក្រមួយចំនួននៅរាជធានីភ្នំពេញបាន និងកំពុងជួបប្រទះជាក់ស្តែង។

ការស្រាវជ្រាវនាពេលអនាគតត្រូវតែធ្វើឡើង ដើម្បីឈ្វេងយល់ពីវិសាលភាពនៃបញ្ហាដែលស្ត្រីដទៃទៀតបាន និងកំពុងប្រឈមទាក់ទងនឹងការតស៊ូ និងបញ្ចេញមតិរបស់ខ្លួននៅលើបណ្តាញទំនាក់ទំនងសង្គមនៅប្រទេសកម្ពុជា។

# ៣. ច្បាប់ជាតិ និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិ

## *ច្បាប់ជាតិ*

**រដ្ឋធម្មនុញ្ញ មាត្រា ៤១.**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់[១]។

**រដ្ឋធម្មនុញ្ញ មាត្រា ៣៥.**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ[២]។

## *កតិកាសញ្ញាអន្តរជាតិ*

***កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៩***

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយ និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ពតាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះតម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់៖

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ។

(ខ) ការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារៈណសុខភាព ឬសីលធម៌សាធារណៈ[៣]។

---

[១] រដ្ឋធម្មនុញ្ញកម្ពុជា [មាត្រា ៤១], ២១ កញ្ញា ១៩៩៣, អាចរកតាមរយៈគេហទំព័រ៖ https://www.refworld.org/docid/3ae6b5428.html [accessed 10 July 2022]

[២] រដ្ឋធម្មនុញ្ញកម្ពុជា [មាត្រា ៣៥], ២១ កញ្ញា ១៩៩៣, អាចរកតាមរយៈគេហទំព័រ៖: https://www.refworld.org/docid/3ae6b5428.html [accessed 10 July 2022]

[៣] មហាសន្និបាតអង្គការសហប្រជាជាតិ, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ,១៦ ធ្នូ ១៩៦៦, អង្គការសហប្រជាជាតិ, លេខ ៩៩៩, មាត្រា ១៩, អាចរកតាមរយៈគេហទំព័រ៖ https://www.refworld.org/docid/3ae6b3aa0.html [accessed 10 July 2022]

## ៤.ការរកឃើញសំខាន់ៗ

### ១. បានទទួលជំនួយពីអង្គការដៃគូ និងសប្បុរសជននានាក្នុងអំឡុងពេលបិទខ្ទប់ និងការសន្យាផ្តល់ដំណោះស្រាយដីធ្លីពីអាជ្ញាធរមូលដ្ឋាន

ស្ត្រី២នាក់ក្នុងចំណោមស្ត្រីទាំង៦នាក់ បានមានប្រសាសន៍ថាតាមរយៈការផ្សព្វផ្សាយពីបញ្ហាដែលសហគមន៍ខ្លួនបានជួបប្រទះ ក្នុងពេលមានវិបត្តិរីករាលដាលនៃជម្ងឺកូវីដ-១៩ សហគមន៍របស់គាត់បានទទួលជាស្បៀងអាហារ និងសម្ភារៈបរិក្ខារសម្រាប់ទប់ស្កាត់ និងបង្ការការរីករាលដាលពីជម្ងឺកូវីដ-១៩ ក្នុងអំឡុងពេលបិទខ្ទប់ពី សាលាខណ្ឌ អង្គការដៃគូ ក៏ដូចជាសប្បុរសជនខាងក្រៅ និងដោះស្រាយទំនាស់ផ្សេងៗដែលកើតមានឡើងក្នុងសហគមន៍របស់ខ្លួន។ ដោយឡែកស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំង៦នាក់ បានបញ្ជាក់ថាតាមរយៈការផ្សព្វផ្សាយពីបញ្ហាដែលសហគមន៍ខ្លួនបានជួបប្រទះជាលទ្ធផល ខាងអាជ្ញាធរមូលដ្ឋាន បានសន្យាថានឹងជួយដោះស្រាយបញ្ហាដីធ្លីរបស់សហគមន៍តាមលទ្ធភាពរបស់អាជ្ញាធរមូលដ្ឋាន។

### ២. សិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិត្រូវបានរឹតត្បិត ក្រោមការបំភិតបំភ័យ និងគំរាមកំហែង

ស្ត្រីទាំងអស់ដែលផ្តល់ការសម្ភាសសុទ្ធតែមានប្រសាសន៍ថា ការចែកចាយព័ត៌មានស្តីពីបញ្ហាប្រឈមរបស់សហគមន៍ពួកគាត់ ក៏ដូចជាការបង្ហោះពីសកម្មភាពប្រជុំនៅក្នុងសហគមន៍ ការប្រារព្ធពិធីសិទ្ធិលំនៅឋាន បញ្ហាដីធ្លីការទាមទារប្លង់កម្មសិទ្ធិស្របច្បាប់ បញ្ហាបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធ ការទទួលបានជំនួយពីសំណាក់អង្គការសង្គមស៊ីវិល និងសប្បុរសជននានា ត្រូវបានរឹតត្បិត ដោយការ បំភិតបំភ័យ និងគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ការរឹតត្បិតសិទ្ធិសេរីភាពនេះធ្វើឡើងក្រោមរូបភាពផ្សេងៗ ដូចជាការដាក់ឱ្យមានកម្លាំងដើម្បីឃ្លាំមើល គំរាមកំហែង និងនាំខ្លួនទៅកាន់ទីតាំងសាលាសង្កាត់ដើម្បីធ្វើការសាកសួរ និងផាកពិន័យជាដើម។

### មីង ចាន់

*"ថ្ងៃម្តៃជាង ខែកញ្ញា ឆ្នាំ២០១៨ នៅក្នុងសហគមន៍របស់ខ្ញុំបានប្រារព្ធពិធី សិទ្ធិលំនៅឋានពិភពលោក ខ្ញុំត្រូវបានអាជ្ញាធរបានមកអញ្ជើញ និងដឹកខ្ញុំនៅទីតាំងនៅក្នុងសហគមន៍ផ្ទាល់តែម្តង ដើម្បីធ្វើការសាកសួរអំពីការប្រារព្ធពិធីនោះរបស់ខ្ញុំ។ នៅពេលដែលខ្ញុំបានទៅដល់ទីតាំងសាលាសង្កាត់ អាជ្ញាធរទាំងនោះសុទ្ធតែជាបុរសបានគំរាមកំហែង និងធ្វើការចោទប្រកាន់ខ្ញុំជាខ្លាំងក្នុងការធ្វើទិវាសិទ្ធិលំនៅឋានពិភពលោក។ រាល់សកកម្មភាពរបស់ពួកគាត់ សុទ្ធតែស្ថិតនៅក្នុងរូបភាពគំរាមកំហែង ដូចជា ការនិយាយស្រែកគំហក។ គាត់ស្រែកខ្លាំងៗថា រាល់សកម្មភាពដែលខ្ញុំបានបង្ហោះមិនត្រឹមត្រូវគួរតែលុបចោលទៅដែលគាត់គិតថាវាជាការចោទប្រកាន់មកលើខាងរាជរដ្ឋាភិបាល និងការទេះតុជាដើម ព្រមទាំងមិនអនុញ្ញាត្តិឱ្យខ្ញុំបន្តធ្វើសកម្មភាពណាដែលប៉ះពាល់រាជរដ្ឋាភិបាល។ ពួកគាត់មិនបានពន្យល់ណែនាំដោយសន្តិវិធី និងផ្តល់ដំណោះស្រាយសមស្របឡើយ គ្រប់រូបភាពសុទ្ធតែជាការរំលោភសិទ្ធ និងការប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរជាខ្លាំង"។*

### មីង បូ

*"ចំពោះបទពិសោធន៍ ក្នុងការប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម បើនិយាយរួមទៅ មិនមានសកម្មភាពអ្វីដែលអាចប្រើប្រាស់បានទេ ដោយសារនៅក្នុងសហគមន៍របស់ខ្ញុំមានការរឹតបន្តឹងខ្លាំង (លើការចែកចាយព័ត៌មាន ក៏ដូចជាការបង្ហោះសកម្មភាពប្រជុំនៅក្នុងសហគមន៍ កិច្ចប្រជុំការសន្សំលុយជាដើម)។ ខ្ញុំមិនអាចធ្វើសកម្មភាពណាទាំងអស់ នៅក្នុងបណ្តាញសង្គមព្រោះតែងតែមានគេតាមដានខ្ញុំ (អ្នកដែលនៅក្នុងសហគមន៍តែពួកគាត់ជាសមាជិកឃុំសង្កាត់) ខ្ញុំដឹងថាពួកគាត់តាមដានខ្ញុំដោយសាររាល់ការបង្ហោះរបស់ខ្ញុំនៅលើបណ្តាញសង្គមតែងមានការនិយាយ មានការណែនាំពីអាជ្ញាធរមិនឱ្យធ្វើនេះ មិនឱ្យធ្វើនោះ ..."។*

## មីង ណា

"...បញ្ហាដីធ្លីនៅក្នុងសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ។ ខ្ញុំបានបង្ហោះពីសកម្មភាពការងារប្រជុំនៅក្នុងសហគមន៍ តែពេលខ្លះខ្ញុំមិនសូវជាបានបង្ហោះនោះទេ ព្រោះមានការរំខានពីអាជ្ញាធរពេក។"

## មីង ស្រី

"ខ្ញុំធ្លាប់បានប្រើប្រាស់ បណ្ដាញសង្គមហ្វេសប៊ុករបស់ខ្ញុំផ្ទាល់ក្នុងការចែកចាយព័ត៌ទាក់ទងនឹងការអភិវឌ្ឍសហគមន៍ ដោយសារខ្ញុំគិតថាវា មិនមែនបញ្ហារបស់ក្រុមគ្រួសារណាមួយនៅក្នុងសហគមន៍នោះទេ តែវាជាបញ្ហាសមាជិកទាំងអស់នៅក្នុងសហគមន៍យើងតែម្ដង យើងត្រូវចេះសាមគ្គីគ្នា ស្វែងរកដំណោះស្រាយ ជាមួយគ្នា។ ក្រោយមកក៏មានការសាកសួរ (ហេតុអ្វីបានជាបង្ហោះសកម្មភាពទាំងនោះ មានគោលបំណងអ្វីដែរក្នុងការបង្ហោះសកម្មភាពទាំងនោះ រាល់ការបង្ហោះនីមួយៗ មិនមែនចេះតែបង្ហោះនោះទេ គួរជៀសវាងការបង្ហោះព័ត៌មានផ្សេងៗដែលប៉ះពាល់អាជ្ញាធរ និងរាជរដ្ឋាភិបាល) ពីខាងអាជ្ញាធរទាក់ទងជាមួយបញ្ហាដែលខ្ញុំបានបង្ហោះនោះ។ ភាគីខាងអាជ្ញាធរបាននិយាយថា មុននឹងធ្វើសកម្មភាពអ្វីមួយនៅក្នុងសហគមន៍គួរតែជូន ដំណឹងទៅកាន់ពួកគាត់ឱ្យដឹងផង ជៀសវាងកើតមានបញ្ហាផ្សេងៗដែលមិនបានដឹងមុន។"

## មីង សុខ

"បញ្ហាដែលសហគមន៍យើងកំពុងជួបប្រទះគឺ ប្លង់កម្មសិទ្ធ និងពិបាកក្នុងការជួបជុំ ប្រជុំផ្សេងៗ។ អ្វីដែលតែងតែបង្ហោះពីការផ្សព្វផ្សាយអ្វីដែលស្រាលៗទេ មិនហ៊ានបង្ហោះអ្វីដែលប៉ះពាល់អាជ្ញាធរទេ ព្រោះពិបាកក្នុងការប្រឈមមុខនឹងអាជ្ញាធរដែល ពួកគាត់តែងតែតាមដាន និងព្រមានមិនឱ្យសមាជិកណាមកបង្ហោះសកម្មភាពដែលប៉ះពាល់ដល់រាជរដ្ឋាភិបាល។"

## មីង យិន

"...ដោយសារការបង្ហោះនេះ មានអាជ្ញាធរដែលមានទីលំនៅ នៅជិតសហគមន៍របស់យើង បានរាយការណ៍ទៅកាន់ចៅសង្កាត់ គេក៏បានចុះមកណែនាំ។ គេមិនចង់ឱ្យយើងមានសកម្មភាពអ្វីទាំងអស់ ចឹងហើយវាមានភាពលំបាកសម្រាប់សហគមន៍យើងផងដែរ។"

## ៣. ភ័យខ្លាចមិនហ៊ានបន្តសកម្មភាពរបស់ខ្លួនទៀត

យ៉ាងហោចណាស់ស្ត្រី៥នាក់ ក្នុងចំណោម៦នាក់ បានបង្ហាញពីការភ័យខ្លាច ក្តីបារម្ភណ៍ មិនបន្ត ឬបន្តបង្ហោះពីការបញ្ចេញមតិ និងពីបញ្ហាផ្សេងៗដែលសហគមន៍ពួកគាត់កំពុងជួបប្រទះ ដោយក្តីបារម្ភថានឹងមានការយាយី និងរំខានពីសំណាក់អាជ្ញាធរក្នុងមូលដ្ឋានរបស់ពួកគាត់។

### មីង យិន

*"ខ្ញុំមានការភ័យជាខ្លាំងក្នុងនាមជាស្ត្រីហើយមានការនាំខ្លួនរបស់ខ្ញុំ ដែលពួកគាត់ជាអាជ្ញាធរដែលសុទ្ធតែជាបុរស កាលពី មុនខ្ញុំក៏ធ្លាប់បានទទួលព័ត៌មានពីខាងសកម្មជនដែលរងគ្រោះដីធ្លីនៅក្នុងសហគមន៍ផ្សេងៗ ដែលមានគេនាំខ្លួនដូចខ្ញុំដែល តែមិនអាចត្រឡប់មកវិញទេ អាចជាការឃាត់ខ្លួន ឬការឃុំខ្លួនមួយរយៈ តែជាសំណាងគេបានអនុញ្ញាតឱ្យខ្ញុំមកផ្ទះវិញ។"*

### មីង ចាន់

*"...នៅពេលដែល គេមកនាំខ្លួនខ្ញុំយកទៅសាកសួរនៅសាលាសង្កាត់ នៅក្នុងខែ កញ្ញា ឆ្នាំ២០១៨ វាស្រដៀងដូចខ្ញុំបានរៀបរាប់ខាងលើដែរ ខ្ញុំតែងតែចែកចាយព័ត៌មាននៅក្នុងសហគមន៍ ដែលមានផលប្រយោជន៍នៅក្នុងសហគមន៍។ ផលវិបាកសម្រាប់ខ្ញុំ មានការហៅទៅជួបនៅសាលាសង្កាត់ និងធ្វើការសាកសួរ(តើសហគមន៍ធ្វើអ្វីក្នុងគោលបំណងអ្វី? ហេតុអ្វីមិនផ្តល់ដំណឹងទៅកាន់អាជ្ញាធរ ដើម្បីចូលរួមក្នុងកិច្ចប្រជុំនោះដែរ?) ដោយក្នុងរូបភាពគំរាមកំហែងខ្ញុំ ពេលនោះខ្ញុំមានការភិតភ័យណាស់ដែរ តែព្យាយាមសម្រួលអារម្មណ៍ទោះស្ថិតនៅក្នុងស្ថានភាពតានតឹងយ៉ាងណាក្តី។"*

### មីង សុខ

*"ខ្ញុំពុំសូវដែលបានបង្ហោះជាសារបញ្ចេញមតិទេ ខ្ញុំប្រើប្រាស់វាសម្រាប់តែកិច្ចការងារក្នុងពិភាក្សាក្រុម រៀបចំផែនការសកម្មភាព ព្រោះខាងអាជ្ញាធរគាត់តែងគំរាមកំហែង ប្រសិនបើខាងប្រជាសហគមន៍ធ្វើខុសអ្វីមួយឬ មានសកម្មភាពមិនប្រក្រតី ពួកគាត់នឹងមិនជួយដោះស្រាយបញ្ហានោះក្នុងសហគមន៍ដូចដែលពួកគាត់បានសន្យានោះទេ។"*

### មីង បូ

*"ចំណែកឯ សមាជិកសហគមន៍ដីទៃទៀតដែលមានទូរស័ព្ទស្មាតហ្វូនប្រើប្រាស់តែងទទួលបានការគំរាមកំហែងពីខាងអាជ្ញាធរ ថាការប្រើប្រាស់របស់ពួកមិនបានត្រឹមត្រូវ មិនត្រូវបង្ហោះសារ ក៏ដូចជាបញ្ហាផ្សេងៗ ដែលកើតមានឡើងនៅក្នុងសហគមន៍ ប្រយ័ត្នគេចាប់ដាក់គុកដូចសហគមន៍ដីទៃទៀត។ ដោយសារតែមានការដាក់សម្ពាធពីអាជ្ញាធរពួកគាត់ក៏លែងមានសកម្មភាពផ្សេងៗទៀត នៅលើបណ្តាញសង្គមទៀត។"*

### មីង ស្រី

*"អាជ្ញាធរដដែលបានបន្តទៀតថា បើបង នៅតែបន្តសកម្មភាពបែបនេះ ប្រយ័ត្នតែមានជាប់ផ្សេងៗ ឬអាចជាប់ពន្ធធនាគាជាដើម។ នៅពេលដែលគាត់និយាយបែបនឹងខ្ញុំមានអារម្មណ៍ភ័យខ្លាចណាស់ដែរ ហើយក៏បានផ្អាកក្នុងការបង្ហោះរូបភាពផ្សេងៗនៅក្នុងបណ្តាញសង្គមផ្ទាល់ខ្លួនរបស់ខ្ញុំ។ ជាមួយគ្នានេះដែរ ប្រហែលជាសមាជិកសហគមន៍របស់ខ្ញុំបានទទួលការគំរាមកំហែងពីអាជ្ញាធរដែរហើយមើលទៅ សមាជិកទាំងអស់ហាក់មានភាពអសកម្មនៅក្នុង សហគមន៍ សូម្បីតែសកម្មភាពក្នុងការចូលរួមកិច្ចប្រជុំក្រុមតូចនៅក្នុងសហគមន៍ជាដើម ពួកគាត់មិនហ៊ានចូលរួមឡើយ ដល់ពេលខ្ញុំបានសួរទៅកាន់ពួកគាត់ ពួកគាត់បាន ប្រាប់មកខ្ញុំថា គាត់មិនចង់មានសកម្មភាពអ្វីនោះទេ ព្រោះគាត់ខ្លាចអាជ្ញាធរមកចាប់ខ្លួនដើម្បីធ្វើការសាកសួរ ឬយកឃុំខ្លួនជាដើម។"*

### ៤. ការបញ្ចុះញ៉ង់ លាបពណ៌នយោបាយ ពីសំណាក់អាជ្ញាធរមូលដ្ឋាន

ម្នាក់ក្នុងចំណោមស្ត្រី ទាំង៦នាក់ បានលើកឡើងថាមានអាជ្ញាធរមូលដ្ឋានមួយរូបបាននិយាយ ថាការផ្តល់ជំនួយដល់សហគមន៍ក្រីក្រពីសំណាក់ស្ថាប័នមិនមែនរាជរដ្ឋាភិបាលគឺជាកិច្ចកលនយោបាយ។

***មីង ស្រី***

*"កាលខ្ញុំចាំមិនភ្លេច ពេលនោះអំឡុងពេលរីករាលដាលនៃជម្ងឺកូវីដ-១៩ អង្គការមួយបានធ្វើការជួយឧបត្ថម្ភ និងចែកជាស្បៀងអាហារ ដើម្បីជួយដោះស្រាយការលំបាកនៅក្នុងសហគមន៍ ព្រោះសមាជិកនៅក្នុងសហគមន៍ទាំងមិនអាចចេញទៅក្រៅបាន និងរកប្រាក់សម្រាប់ផ្គត់ផ្គង់ជីវភាពដែរ។ បន្ទាប់ពីទទួលបានការជួយពីស្ថាប័នមួយនោះខ្ញុំថតសកម្មភាពទាំងនោះ រួចបានបង្ហោះវានោះក្នុងបណ្តាញសង្គមរបស់ខ្លួនខ្ញុំផ្ទាល់ ថ្ងៃមួយអាជ្ញាធរមួយរូបបាន ហាមឃាត់ខ្ញុំមិនឱ្យធ្វើការបង្ហោះជារូបភាពបែបនឹងទៅលើបណ្តាញសង្គម គាត់បាននិយាយបន្ថែមទៀតថា នៅក្នុងហ្វេសប៊ុកមិនមែនចេះតែបង្ហោះនោះទេ ព្រោះការផ្តល់ជំនួយដល់សហគមន៍ក្រីក្រដូចបងស្រី មិនស្ថិតនៅក្នុងរូបភាពនៅក្នុងការជួយនោះទេ សុទ្ធតែស្ថិតនៅក្នុងកិច្ចកលនយោបាយ មិនដែលគេមានចិត្តជួយសហគមន៍បងស្រីដោយសុទ្ធតែចិត្តនោះទេ"។*

## ៥. សេចក្តីសន្និដ្ឋាន

ស្ត្រីជាអ្នកដឹកនាំ និងតំណាងសហគមន៍ក្រីក្រ ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមរបស់ខ្លួនតស៊ូមតិដើម្បីសិទ្ធិ និងទទួលបានដំណោះស្រាយពីបញ្ហាប្រឈមរបស់ពួកគេ។ ជាលទ្ធផលពួកគេអាចទទួលបានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងសាធារណជនក្នុងអំឡុងពេលកូវីដ-១៩ ដោយប្រើវិធីសាស្ត្រទាំងនេះ។ ប៉ុន្តែការការបញ្ចេញមតិ និងបង្ហាញពីបញ្ហាប្រឈមនានារបស់ពួកគេនៅលើបណ្តាញទំនាក់ទំនងសង្គម ក៏បានទទួលការចាប់អារម្មណ៍ជាអវិជ្ជមានពីសំណាក់អាជ្ញាធរមូលដ្ឋានរបស់ពួកគេផងដែរ។ ជារឿយៗអាជ្ញាធរមូលដ្ឋានបានចាត់ទុកការតស៊ូមតិ និងការនិយាយស្តីពីបញ្ហាប្រឈមនៅក្នុងសហគមន៍របស់ស្ត្រីខាងលើ ថាជាការប្រឆាំងនឹងរាជរដ្ឋាភិបាល។ ទន្ទឹមនឹងការទទួលបានជំនួយពីសប្បុរសជន និងអង្គការជាដៃគូរក្នុងអំឡុងពេលបិទខ្ទប់ និងការសន្យាពីដំណោះស្រាយដីធ្លីពីសំណាក់អាជ្ញាធរ ស្ត្រីទាំងដែលបានផ្តល់ការសម្ភាសសម្រាប់របាយការណ៍នេះ សុទ្ធតែបានរាយការណ៍ពីការរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញតស៊ូមតិ ការនិយាយពីបញ្ហាប្រឈមនានា នៅលើបណ្តាញទំនាក់ទំនងសង្គមរបស់ពួកគេ និងការបាត់បង់ឆន្ទៈក្នុងការបន្តនិយាយពីបញ្ហារបស់ពួកគេនៅលើបណ្តាញទំនាក់ទំនងសង្គមដោយភាពភ័យខ្លាច។

## ៦. អនុសាសន៍

- ការពារ គោរព និងធានាឱ្យប្រជាពលរដ្ឋមាន សិទ្ធិនឹងសេរីភាពបញ្ចេញមតិ ស្របតាមរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចក្នុងនាមជា រដ្ឋហត្ថលេខី និងជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ អាជ្ញាធរមូលដ្ឋានគួរលើកទឹកចិត្តប្រជាពលរដ្ឋឱ្យធ្វើការបញ្ចេញមតិ និងបង្ហាញពីបញ្ហាដែលប្រជាពលរដ្ឋ និងសហគមន៍របស់ខ្លួនបាននឹងកំពុងជួបប្រទះ ហើយជួយនិងចូលរួមដោះស្រាយបញ្ហា ឬកង្វល់ទាំងនោះដោយមិនមានការដោះដូរ និងមិនចាត់ទុកការបញ្ចេញមតិ និងបង្ហាញពីបញ្ហារបស់ប្រជាពលរដ្ឋ នៅលើបណ្តាញផ្សព្វផ្សាយសង្គមថាជាការប្រឆាំងនឹងរាជរដ្ឋាភិបាល។
- រដ្ឋបាលថ្នាក់ជាតិគួរពិនិត្យលើការអនុវត្តចំពោះការការពារ គោរព និងធានាសិទ្ធពលរដ្ឋពលរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោយជាតិរបស់ខ្លួន និងបញ្ឈប់រាល់ការបំភិតបំភ័យតាមគ្រប់រូបភាព នៅពេលប្រជាពលរដ្ឋធ្វើការបញ្ចេញមតិ និងបង្ហាញពីបញ្ហាប្រឈមរបស់សហគមន៍ខ្លួន។
- អនុវត្តគោលនយោបាយ "លើកកម្ពស់ប្រសិទ្ធភាពនៃគោលនយោបាយសុខដុមនីកម្មសង្គមទាំងមូល ប្រឆាំងរាល់ទម្រង់នៃការរើសអើង បែងចែកក្នុងសង្គម" ដែលមានចែងក្នុងគោលនយោបាយបោះឆ្នោតឃុំ សង្កាត់នាខែមិថុនា ឆ្នាំ២០២២ កន្លងទៅថ្មីនេះ[៩]។

---

[៩] គោលនយោបាយបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់, "លើកកម្ពស់ប្រសិទ្ធភាពនៃគោលនយោបាយសុខដុមនីកម្មសង្គមទាំងមូលប្រឆាំងរាល់ទម្រង់នៃការរើសអើង បែងចែកក្នុងសង្គម", ខែមិថុនា ឆ្នាំ ២០២២ (បានបិតផ្សាយក្នុងសហគមន៍កំឡុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្នុងខែមិថុនា ឆ្នាំ ២០២២)



អង្គការសមាគមធាងត្នោត

**Sahmakum Teang Tnaut Organization** • a Cambodian Urban NGO


ទូរស័ព្ទទំនាក់ទំនង៖ (855) 23 555 1964

គេហទំព័រ៖ www.teangtnaut.org

សំឡេងទីក្រុង៖https://urbanvoicecambodia.net

ហ្វេសប៊ុក៖https://www.facebook.com/sttcambodia